00293434

C22/5/34

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៣០ មីនា ២០០៩

---

**សាធារណៈ:**

**សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់លោក អៀង សារី សុំឲ្យទទួលបណ្ឌិត PAULUS FALKE ផ្តល់ភស្តុតាងកោសល្យវិច័យ នៅក្នុងពេលសវនាការដេញដោល ផ្ទាល់មាត់ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

**សហមេធាវីការពារក្តី**

អាង ឧត្តម
MichaelG. ARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 31 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fay

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 03 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fay

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00293435

C22/5/34

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញ "សំណើជាបន្ទាន់របស់ **អៀង សារី** សុំឱ្យវេជ្ជបណ្ឌិត PAULUS FALKE ផ្តល់ភស្តុតាងកោសល្យវិច្ច័យ នៅក្នុងពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩" ដែលសំណើនេះត្រូវបានដាក់កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩។

## I. **ប្រវត្តិនីតិវិធី**

២. នៅក្នុងសំណើរបស់ខ្លួន សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖

ក. "[តែងតាំង] វេជ្ជបណ្ឌិត Paulus Falke [...] ធ្វើជាអ្នកជំនាញវេជ្ជសាស្ត្រ។

ខ. "អនុញ្ញាតឱ្យវេជ្ជបណ្ឌិត Falke ផ្តល់ភស្តុតាងកោសល្យវិច្ច័យ នៅក្នុងពេលសវនាការដេញដោលផ្ទាល់មាត់ នាថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ខាងមុខនេះ" និង

គ. ណែនាំភាគីទាំងអស់ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងលេខ០០២ ឱ្យដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសំណើនេះ ឱ្យបានត្រឹមថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ដើម្បីផ្តល់លទ្ធភាពឱ្យអង្គបុរេជំនុំជម្រះ អាចធ្វើការវិនិច្ឆ័យទៅលើសំណើនេះបានទាន់ពេលវេលា ដើម្បីឱ្យផ្នែកការពារក្តី និងផ្នែកគ្រប់គ្រងតុលាការអាចធ្វើការរៀបចំចាត់ចែងឱ្យវេជ្ជបណ្ឌិត Falke ផ្តល់នូវភស្តុតាងតាមរយៈបណ្តាញវីដេអូ"[1]។

៣. នៅក្នុងសំណើនោះ សហមេធាវីការពារក្តីបានលើកឡើងថា អង្គហេតុដែលអង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យមានការពិភាក្សាគ្នាយ៉ាងលំអិតទៅលើរបាយការណ៍វេជ្ជសាស្ត្ររបស់លោក អៀង សារី នាពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដែលបានប្រព្រឹត្តឡើងកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ កន្លងទៅនេះ បានបង្ហាញថា "មតិយោបល់របស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រគឺមានសារៈសំខាន់យ៉ាងជាក់ច្បាស់ និងដោយផ្ទាល់ពាក់ព័ន្ធទៅនឹងសវនាការដេញដោលផ្ទាល់មាត់ ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្នប្រាកដ

---

[1] សំណើជាបន្ទាន់របស់លោក អៀង សារី សុំឱ្យលោកវេជ្ជបណ្ឌិត PAULUS FALKE ផ្តល់ភស្តុតាងកោសល្យវិច្ច័យ នៅក្នុងពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ("សំណើ") កឋាខណ្ឌទី១ និងទី៣។

មែន”[2]។ សហមេធាវីការពារក្តីបានអះអាងថា វេជ្ជបណ្ឌិត Falke “គឺជាអ្នកជំនាញ ដែលមានលក្ខណៈសម្បត្តិពិសេសជាងគេ ក្នុងការជួយឱ្យអង្គបុរេជំនុំជម្រះ បានយល់ពីរបាយការណ៍វេជ្ជសាស្ត្រផ្សេងៗស្តីពី [លោក អៀង សារី...] និងផលប៉ះពាល់នៃការឃុំខ្លួនដែលអូសបន្លាយមកលើសុខភាពអ្នកជាប់ឃុំឃាំង”[3]។ សហមេធាវីការពារក្តីបានធ្វើការពន្យល់ថា “ទោះបីជាពុំមានលក្ខខណ្ឌតម្រូវឱ្យអ្នកជំនាញផ្តល់ភស្តុតាងដោយផ្ទាល់ក៏ដោយ” គោលបំណងក្នុងការផ្តល់ភស្តុតាងរបស់វេជ្ជបណ្ឌិត Falke គឺដើម្បីពន្យល់អំពី “នីតិវិធីដែលបានអនុវត្តដោយវេជ្ជបណ្ឌិតរបស់អ.វ.ត.ក” និងដើម្បីវាយតម្លៃ “ថាតើវេជ្ជបណ្ឌិត និងអ្នកជំនាញទាំងនេះ ប្រើប្រាស់វិធានការណ៍ដល់កម្រិតអន្តរជាតិដែរឬទេ”[4]។

៤. នៅក្នុងសេចក្តីណែនាំចេញថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានអញ្ជើញភាគី ដែលពាក់ព័ន្ធនៅក្នុងរឿងក្តី ឱ្យដាក់សេចក្តីសន្និដ្ឋានតបចំពោះសំណើនេះ ត្រឹមថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩[5]។

៥. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ “ចម្លើយរបស់ខ្លួនតបទៅនឹងសំណើរបស់លោក អៀង សារី សុំឱ្យវេជ្ជបណ្ឌិតពិនិត្យ នាពេលសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍របស់គាត់ស្តីពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន” ដែលនៅក្នុងចម្លើយតបនោះ សហព្រះរាជអាជ្ញាបានស្នើដល់អង្គបុរេជំនុំជម្រះ “ឱ្យច្រានចោលនូវពាក្យសុំលើកទីពីរ” នេះ។ សហព្រះរាជអាជ្ញាបានលើកឡើងថាៈ “១) ដើមបណ្តឹងឧទ្ធរណ៍មិនបានដាក់ឯកសារថ្មីណាមួយ ឬមិនបានបង្ហាញនូវកាលៈទេសៈផ្លាស់ប្តូរថ្មីសំខាន់ណាមួយ សម្រាប់ឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញលើដីកាសម្រេចច្រានចោលលើកទីមួយរបស់ខ្លួននោះឡើយ។ ២) ទោះបីជាអង្គបុរេជំនុំជម្រះទទួលយកនូវពាក្យសុំលើកទីពីរនោះក៏ដោយ ក៏ពាក្យសុំលើកទីពីរនោះមិនស្របទៅតាមលក្ខខណ្ឌ

---

[2] សំណើ កឋាខណ្ឌទី២។

[3] សំណើ កឋាខណ្ឌទី៧ និងទី៨។

[4] សំណើកឋាខណ្ឌទី៩។

[5] សេចក្តីបង្គាប់ដល់ភាគីទាក់ទងនឹងសំណើជាបន្ទាន់របស់លោក អៀង សារី សុំឱ្យលោកវេជ្ជបណ្ឌិត PAULUS FALKE ផ្តល់ភស្តុតាងកោសល្យវិច្ច័យ នៅក្នុងពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩, C22/5/29។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C.

តម្រូវ នៃបទបញ្ញត្តិច្បាប់ដែលជាទីសម្អាងក្នុងការដាក់ពាក្យសុំនោះឡើយ។ ៣) វេជ្ជបណ្ឌិត Falke មិនមានគុណវុឌ្ឍិជាអ្នកជំនាញក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះទេ [ហើយ] ទោះបីជា [គាត់] ជាអ្នកជំនាញក៏ដោយ ក៏របាយការណ៍សង្ខេបរបស់គាត់មិនមានលក្ខណៈសម្បត្តិជារបាយការណ៍ជំនាញដែរ។ ៤) ពាក្យសុំលើកទីពីរនេះគឺមានលក្ខណៈខ្ជះខ្ជាយទាំងពេលវេលា និងធនធានតុលាការ និងធ្វើឱ្យអន្តរាយដល់សេដ្ឋកិច្ចតុលាការថែមទៀតផង”[6]។

៦. មកដល់ពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មេធាវីតំណាងពួកគេ ពុំទាន់បានដាក់ចម្លើយតបចំពោះសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងសំណើសុំនៅឡើយទេ។

## II. ការពិនិត្យពិចារណា

៧. នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណើរបស់ អៀង សារី សុំឱ្យកោះអញ្ជើញអ្នកជំនាញវេជ្ជសាស្ត្រ ឱ្យផ្តល់ភស្តុតាងក្នុងពេលសវនាការដោយផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះបានយល់ឃើញដូចខាងក្រោម:

> “នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន លើដីកាសម្រេចបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្ន សហមេធាវីការពារក្តីរបស់ជនត្រូវចោទមិនបានលើកឡើងអំពីបញ្ហាចោទណាមួយ ពាក់ព័ន្ធនឹងស្ថានភាពសុខភាពរបស់ជនត្រូវចោទនោះទេ លើកលែងតែសេចក្តីយោងដ៏ខ្លីមួយប៉ុណ្ណោះ ដែលបានសរសេរនៅក្នុងកថាខណ្ឌ៥៣ នៃសារណាបណ្តឹងឧទ្ធរណ៍នោះ។ សេចក្តីយោងមានខ្លឹមសារដូចខាងក្រោម:
>
> > “ករណីនៃការឃុំខ្លួននៅក្នុងផ្ទះ គឺត្រូវធ្វើដោយយោងលើស្ថានភាពអាយុ និងសុខភាពមិនល្អរបស់លោក អៀង សារី ដែលជាមូលដ្ឋានសម្រាប់អង្គជំនុំជម្រះ ក្នុងការ

[6] សហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងពាក្យសុំរបស់ អៀង សារី ឱ្យពិនិត្យលើវេជ្ជបណ្ឌិតម្នាក់នៅពេលសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍របស់គាត់ស្តីពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន , C22/5/30 កថាខណ្ឌទី២។ សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំឱ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រ

អនុវត្តន៍នូវឆន្ទានុសិទ្ធដែលអនុញ្ញាតដោយវិធាន ៦៣(៣) និងបង្គាប់ឱ្យដោះលែង លោក អៀង សារី នៅក្រោមលក្ខខណ្ឌដែលមានកំហិតតិច នៃការឃុំខ្លួននៅក្នុង ផ្ទះ”[7]។

នៅក្នុងសំណើសុំឱ្យកោះអញ្ជើញសាក្សីនានា សហមេធាវីការពារក្តីមិនបានលើកឡើងអំពីមូលហេតុ ដែលចង់ឱ្យមានការស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គបុរេជំនុំជម្រះនោះទេ ដែលមូលហេតុនោះអាចធ្វើឱ្យមានការសន្និដ្ឋានថា ការស្តាប់ចម្លើយសាក្សីនឹងជួយបន្ថែមនូវការគាំទ្រដល់សេចក្តីសម្អាង ដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី។

អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីមិនបានលើកឡើងនៅក្នុងសំណើសុំអំពីថាតើមានកាលៈទេសៈថ្មី ដែលបានកើតឡើងក្រោយពីបានដាក់សារណាបណ្តឹងឧទ្ធរណ៍រួចហើយ ដែលអាចធ្វើឱ្យមានយុត្តិកម្មចំពោះស្ថានភាពចាំបាច់ក្នុងការស្តាប់ចម្លើយសាក្សីនៅក្នុងបណ្តឹងឧទ្ធរណ៍ដែរឬទេ”[8]។

៨. លើសពីនេះទៅទៀត នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ នៅក្នុង “សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណើដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងអំឡុងពេលសវនាការ ដែលបានប្រព្រឹត្តទៅនៅថ្ងៃខែឆ្នាំដដែល” អង្គបុរេជំនុំជម្រះបានបដិសេធចោលសំណើរបស់សហមេធាវីការពារក្តីសុំឱ្យស្តាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិត Falke ក្នុងឋានៈជាសាក្សី ពីព្រោះ “សំណើនេះគឺសុំឱ្យស្តាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិត Falke ក្នុងឋានៈជាសាក្សី មិនមែនជាសំណើតែងតាំងគាត់ជាអ្នកជំនាញនោះទេ។ ភស្តុតាងដែលគាត់អាចផ្តល់ជូនបានគឺជាភស្តុតាងប្រយោល”[9]។

---

[7] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ C/២២/៥/១ កឋាខណ្ឌទី៥៣។

[8] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើរបស់អៀង សារី សុំឱ្យកោះអញ្ជើញអ្នកជំនាញវេជ្ជសាស្ត្រ, C22/5/18 ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩។

[9] សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណើដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍របស់ អៀង សារី , C22/5/24 ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩។

៩. នៅក្នុងសំណើ ដែលបានដាក់កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ កន្លងមកនេះ ទីមួយសហមេធាវីការពារក្តីបានស្នើសុំឱ្យតែងតាំងវេជ្ជបណ្ឌិត Falke ជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងទីពីរបានស្នើសុំឱ្យកោះអញ្ជើញគាត់ចូលរួមសវនាការដេញដោលផ្ទាល់មាត់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ ខាងមុខនេះ។ ដោយមានលក្ខណៈផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះបានរកឃើញថា សំណើនេះមិនមែនជាសំណើសុំឱ្យធ្វើការពិចារណាសារឡើងវិញលើសំណើមុនរបស់សហមេធាវីការពារក្តី ដែលគ្រាន់តែសុំឱ្យកោះអញ្ជើញវេជ្ជបណ្ឌិត Falke ចូលរួមក្នុងសវនាការដេញដោលផ្ទាល់មាត់ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលត្រូវបានបដិសេធចោលរួចហើយនោះទេ[10]។

១០. សហមេធាវីការពារក្តីបានសន្និដ្ឋានថា ពួកគាត់ចង់ឱ្យវេជ្ជបណ្ឌិត Falke ជួយដល់អង្គបុរេជំនុំជម្រះក្នុងការស្វែងយល់ “អំពីរបាយការណ៍វេជ្ជសាស្ត្រផ្សេងៗ” និង “ផលប៉ះពាល់នៃការឃុំខ្លួនដែលអូសបន្លាយមកលើសុខភាពអ្នកជាប់ឃុំឃាំង”។

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នីតិវិធីនៃបណ្តឹងឧទ្ធរណ៍នេះទាក់ទងនឹងការឃុំខ្លួនជនត្រូវចោទជាក់លាក់មួយរូប។ វាអាចមានការស្រាវជ្រាវជាច្រើន ឬក៏អាចមានអ្នកជំនាញមួយចំនួន ដែលអាចផ្តល់មតិយោបល់ផ្នែកជំនាញទូទៅលើអ្វីដែលជាផលប៉ះពាល់ទូទៅនៃការឃុំខ្លួនដែលអូសបន្លាយមកលើសុខភាពអ្នកជាប់ឃុំឃាំង។ ប្រសិនបើអង្គបុរេជំនុំជម្រះធ្វើការពិចារណាទៅលើផលប៉ះពាល់នៃការឃុំខ្លួន ដែលអូសបន្លាយមកលើសុខភាពរបស់លោក អៀង សារី នោះ វាគួរតែយោងតែទៅលើរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញទាំងឡាយណាដែលមានឱកាសបានពិនិត្យសុខភាពរបស់គាត់ដោយផ្ទាល់ ជាជាងយោងទៅលើរបាយការណ៍ដែលពន្យល់អំពីផលប៉ះពាល់បែបនោះជាលក្ខណៈទ្រឹស្តី ឬក៏យោងទៅលើបទពិសោធន៍ផ្សេងៗទៀត។ បញ្ហាចោទដែលអង្គបុរេជំនុំជម្រះបានទទួលនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍នេះ មានការពាក់ព័ន្ធដល់បុគ្គលជាក់លាក់មួយរូប និងត្រូវតែដោះស្រាយទៅតាមនោះដែរ។ អង្គបុរេជំនុំ

---

[10] សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ លើសំណើដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍របស់ អៀង សារី , C22/5/24 ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨។

00293440



ជម្រះ បានកត់សម្គាល់ឃើញដែរថា អ្នកជំនាញត្រូវបានចាត់តាំងរួចហើយដើម្បីឱ្យផ្តល់របាយការណ៍វេជ្ជសាស្ត្រស្តីពីស្ថានភាពសុខភាពរបស់លោក អៀង សារី។

១២. សំណើមួយនេះត្រូវបានដាក់ ដោយយោងតាមការសន្មតរបស់សហមេធាវីការពារក្តីថា បញ្ហាសុខភាពរបស់ជនត្រូវចោទ គឺជាផ្នែកមួយដ៏សំខាន់នៃបណ្តឹងឧទ្ធរណ៍ ដោយហេតុនេះ សហមេធាវីការពារក្តីលើកឡើងថា វាជាការចាំបាច់ណាស់ក្នុងការតែងតាំងអ្នកជំនាញ ដើម្បីជួយដល់អង្គបុរេជំនុំជម្រះ ឱ្យបានយល់អំពីរបាយការណ៍វេជ្ជសាស្ត្រផ្សេងៗ ស្តីពីសុខភាពរបស់ជនត្រូវចោទ។

១៣. រហូតមកដល់ថ្ងៃនេះ របាយការណ៍វេជ្ជសាស្ត្រដែលត្រូវបានសម្អាងនោះមិនមែនជាផ្នែកមួយនៃបណ្តឹងឧទ្ធរណ៍នោះទេ សហមេធាវីការពារក្តីក៏មិនបានស្នើទេថា ស្ថានភាពសុខភាពរបស់ជនត្រូវចោទបានក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការប្តឹងឧទ្ធរណ៍ នៅក្នុងដំណាក់កាលនេះនៃនីតិវិធី។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមិនត្រូវការជំនួយ ដើម្បីពន្យល់ពាក្យបច្ចេកទេសវេជ្ជសាស្ត្រនោះទេ។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ប្រសិនបើអង្គបុរេជំនុំជម្រះត្រូវការជំនួយដើម្បីពន្យល់អំពីរបាយការណ៍នានានោះ អង្គបុរេជំនុំជម្រះគួរតែស្វែងរកជំនួយនេះពីអ្នកជំនាញ ដែលមានស្រាប់ដោយខ្លួនឯង ពីព្រោះថាអ្នកជំនាញទាំងនេះហើយដែលត្រូវតែធ្វើការពន្យល់អំពីរបាយការណ៍របស់ខ្លួននោះ។

១៤. ប្រសិនបើសំណើសុំណាមួយត្រូវបានធ្វើឡើង ដោយមានបញ្ចូលទាំងស្ថានភាពសុខភាពក្នុងបណ្តឹងឧទ្ធរណ៍មួយនេះ និងនៅក្នុងសំណើនោះ បញ្ហាសុខភាពគឺជាសំណើមួយ ដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះធ្វើសេចក្តីសន្និដ្ឋានតាមរបាយការណ៍វេជ្ជសាស្ត្រនានានោះ អង្គបុរេជំនុំជម្រះអាចធ្វើដូច្នេះបាននៅក្នុងដំណាក់កាលបន្ទាប់ទៀត នៅពេលណាដែលអង្គបុរេជំនុំជម្រះបានកំណត់អំពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍នោះរួចហើយ។ អ្នកជំនាញវេជ្ជសាស្ត្រអាចត្រូវបានកោះហៅឱ្យបញ្ចេញយោបល់ ក្នុងករណីដែលអង្គបុរេជំនុំជម្រះរកឃើញថា យោបល់អ្នកជំនាញនេះមានភាពចាំបាច់ក្នុងការធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC

00293441

C22/5/34



១៥. ប្រសិនបើអ្នកជំនាញត្រូវបានតែងតាំងបន្ថែមទៀតដោយអង្គបុរេជំនុំជម្រះ ការតែងតាំងទាំងនេះត្រូវធ្វើឡើងដោយយោងតាមវិធានផ្ទៃក្នុង ដែលតម្រូវឱ្យអ្នកជំនាញទាំងនេះធ្វើការ "ត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ផ្នែកវិកលចរិក និងផ្នែកចិត្តសាស្ត្រ" ទៅលើជនត្រូវចោទសិន[11]។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ៖**

**បដិសេធចោល** សំណើជាបន្ទាន់របស់លោក អៀង សារី សុំឱ្យលោកវេជ្ជបណ្ឌិត PAULUS FALKE ផ្តល់ភស្តុតាងកោសល្យវិច្ច័យ នៅក្នុងពេលសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨។

ភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៨

ប្រធានអង្គបុរេជំនុំជម្រះ

ប្រាក់ គឹមសាន

[11] មើលវិធាន៣២ នៃវិធានផ្ទៃក្នុងអ.វ.ត.ក។